Malgré les nombreuses possibilités encore à explorer et tout le potentiel à développer, Sa Sa Art Projects est également limité par sa nature propre. Le financement est un souci constant, l'organisation étant par définition instructurée. Le fait que Samnang, Sokchanlina et moi même sommes les seuls acteurs clés dans les Projects - et que nous sommes également constamment à devoir produire des efforts pour nos propres pratiques artistiques individuelles – n'est pas sans présenter de risques. Cependant cette aptitude aux transitions dans ce que nous entreprenons est essentielle à la pertinence locale de Sa Sa Art Projects. Il en va de même avec cette constante conscience et ré-évaluation de nos propres forces tout comme des forums d'interaction avec un Cambodge contemporain en continuelle mutation . Dans le contexte actuel de la rareté en formation en art et de l'engagement limité pour les Cambodgiens du quotidien avec l'art, Stiev Selapak et Sa Sa Art Projects s'efforcent de partager, apprendre, collaborer, s'engager et se développer dans un esprit d'éducation libre et gratuite et de partage en commun.

[9] *White Building*, www.whitebuilding.org.

UDAYA, Journal of Khmer Studies, 12, 2014

# ចែករំលែកចំណេះដឹង និងរៀនជាមួយគ្នា ៖ ការប្រឡូកចូលរួមក្នុងសិល្បៈពីក្រុមស្ទាវសិល្បៈ និងគម្រោងសិល្បៈស-ស[1]

*ដោយ វុធ លីណូ*
គម្រោងសិល្បៈស-ស

*អត្ថបទនេះរៀបរាប់អំពីប្រវត្តិនៃក្រុមស្ទាវសិល្បៈ និងបម្រែបម្រួលនៃការផ្ដួចផ្ដើមរបស់ក្រុមនេះនៅក្នុងវិស័យសិល្បៈសហសម័យខ្មែរ។ បន្ទាប់ពីបានជួបគ្នានៅក្នុងវគ្គបណ្ដុះបណ្ដាលជំនាញថតរូបនៅឯបន្ទប់តាំងរូបថតពពិលនៅក្នុងឆ្នាំ២០០៧រួចមកបុគ្គលចំនួន៦រូបដែលមានសាវតារដោយឡែកៗពីគ្នាបានសម្រេចចិត្តចងក្រងជាក្រុមដើម្បីចែករំលែកចំណេះដឹង និងអភិវឌ្ឍជំនាញសិល្បៈជាមួយគ្នា។ យើងបានចាប់ផ្ដើមដោយជួបពិភាក្សានិងចែករំលែកគំនិតគ្នាដោយពុំមានទីតាំងជាអចិន្ត្រៃយ៍នោះទេ។នៅឆ្នាំ២០០៩យើងបានបង្កើតវិចិត្រសាលមួយ ដើម្បីគាំទ្រដល់សិល្បករខ្មែរវ័យក្មេង។បន្ទាប់មកនៅឆ្នាំ២០១០យើងបានផ្លាស់ប្ដូរមកបង្រៀនថតរូបនិងគំនូរចម្លាក់សេរី និងរៀបចំគម្រោងសហការជាមួយសហគមន៍ តាមរយៈគម្រោងសិល្បៈស-ស។"ស-ស"គឺជាគម្រោងសិល្បៈសាកល្បងនិងវិវត្តជាប្រចាំ ហើយមានទីតាំងនៅក្នុងអគារប៊ូឌីង ដែលជាអគារប្រវត្តិសាស្ត្រ និងជាសហគមន៍មានចំណូលទាបតែសកម្មនិងច្នៃប្រឌិតនៅក្នុងទីក្រុងភ្នំពេញ។ អត្ថបទនេះបង្ហាញពីស្មារតីចែករំលែកចំណេះដឹងនិងរចនាសម្ព័ន្ធប្រែប្រួលរបស់ក្រុមស្ទាវសិល្បៈ និងគម្រោងសិល្បៈស-សជាជាគំរូនៃលទ្ធភាពមួយបែបនៃការប្រឡូកចូលរួមក្នុងវិស័យសិល្បៈនៅក្នុងកាលៈទេសៈកម្ពុជាបច្ចុប្បន្នដែលមានការអប់រំផ្នែកសិល្បៈមិនគ្រប់គ្រាន់ការពឹងផ្អែកលើជំនួយបរទេសដ៏ជោគជាំបរិយាកាសនយោបាយតានតឹង និងភាពស្ងួចស្ដើងនៃការចូលរួមពីសំណាក់ប្រជាជនខ្មែរសាមញ្ញនៅក្នុងវិស័យសិល្បៈសហសម័យ។*

* * * * *

[1] *អត្ថបទនេះគឺការវិវត្តបន្តពីអត្ថបទដែលខ្ញុំបានបង្ហាញនៅឯសន្និសិទ្* Contemporary Art in Cambodia: A Historical Inquiry *កាលពីថ្ងៃទី ២១ មេសា ២០១៣ នៅសារមន្ទីរសិល្បៈទំនើប* (MoMA) *ទីក្រុងញូយ៉ក។*

ក្នុងថ្ងៃមួយចុងឆ្នាំ២០០៥ខ្ញុំបានសម្រាកពីការងារ ហើយសម្រេចចិត្តជិះម៉ូតូកំសាន្តក្នុងក្រុង។ ខ្ញុំបានគិតថា វាពិតជាមានសេរីភាពណាស់ ដែលអាចធ្វើដំណើរតាមដងផ្លូវតូចៗក្នុងក្រុងភ្នំពេញ ដោយមិនមានគោលដៅឬការចាំបាច់បន្ទាន់ដើម្បីទៅកាន់ទីណាទេនោះ គឺគ្រាន់តែទស្សនានិងឲ្យតម្លៃដល់ដំណើរជីវិតនៅជុំវិញយើង។ នៅខាងជើងបន្តិចពីវត្តសារវន្តលើបណ្តោយផ្លូវលេខ១៩ ខ្ញុំបានឃើញផ្ទះល្វែងទំនើបមួយមានដាក់ផ្លាក"ពពិលបន្ទប់តាំងរូបថត Popil Photo Gallery"។ ខ្ញុំភ្ញាក់ភ្ញាមព្រោះខ្ញុំមិនដែលឃើញមានវិចិត្រសាលរូបថតនៅក្នុងទីក្រុងពីមុនមកទេ។ ខ្ញុំបានសួរខ្លួនឯងថា "មែនឬ?"។ ដោយសារខ្ញុំបានអនុវត្តការងារថតរូបផង (បើទោះបីជាការថតរូបរបស់ខ្ញុំនៅពេលនោះច្រើនតែជាការងារបែបទំនាក់ទំនងនិងផ្សព្វផ្សាយសម្រាប់អង្គការដែលខ្ញុំធ្វើការជាមួយក៏ដោយ) ខ្ញុំបានចាប់អារម្មណ៍និងចង់ដឹងយ៉ាងខ្លាំង។ ខ្ញុំក៏បានចតម៉ូតូ និងដើរចូលទៅកាន់វិចិត្រសាលនោះ។ វាជាផ្ទះល្វែងមួយដែលត្រូវបានជួសជុលជាថ្មី និងកែច្នៃយ៉ាងស្អាតទៅជាសាលមួយដ៏វែងមានជញ្ជាំងពណ៌ស ហើយមានបង្អួចកញ្ចក់ជាច្រើននៅខាងមុខសម្រាប់ឲ្យពន្លឺចូលគ្រប់គ្រាន់។ មានរូបថតធំៗប្រហែលជាជាង១០ផ្ទាំងដែលបានដាក់តាំងបង្ហាញ ដោយរូបខ្លះព្យួរលើជញ្ជាំង និងរូបខ្លះទៀតដាក់បញ្ឈរលើវត្ថុប្រើប្រាស់ក្នុងផ្ទះផ្សេងៗ។ វាគឺជាពិព័រណ៍ជាក្រុមនៃរូបថតបែបសិល្បៈនិងរូបថតបែបឯកសារ ដោយខ្លះទំនងជារូបថតកាលពីទសវត្សរ៍មុន ហើយខ្លះទៀតទំនងជារូបថតថ្មីៗ។ ខ្ញុំបានចាប់អារម្មណ៍ជាខ្លាំង។

មិនយូរប៉ុន្មាន បន្ទាប់ពីខ្ញុំបានរីករាយជាមួយនឹងបទពិសោធន៍ទស្សនាវិចិត្រសាលរូបថតក្នុងទីក្រុងភ្នំពេញជាលើកទីមួយរបស់ខ្ញុំមកបុរសម្នាក់បានលេចពីតុធ្វើការរបស់គាត់ពីចុងបន្ទប់។ គាត់បានទទួលស្វាគមន៍ខ្ញុំនិងណែនាំខ្លួនគាត់ថាឈ្មោះ ស្តេហ្វិន ចានីន (Stéphane Janin) ហើយគាត់ជាអ្នកថតរូប និងជានាយកនៃវិចិត្រសាលនេះ។ គាត់បានពន្យល់ខ្ញុំថារូបថតទាំងនេះគឺជាជាស្នាដៃរបស់អ្នកថតរូបខ្មែរ ម៉ក់ រ៉េមីស្សា និងវណ្ណឌី រតនា និងរូបថតរបស់គាត់ផ្ទាល់។ បន្ទាប់មក ស្តេហ្វិន បានបង្ហាញខ្ញុំជាន់លើនៃវិចិត្រសាល ដែលគាត់មានដាក់បង្ហាញជាអចិន្ត្រៃយ៍នូវស្នាដៃរូបថតរបស់អ្នកថតរូបផ្សេងៗជាច្រើនទៀតព្រមទាំងសៀវភៅរូបថតមួយចំនួនទៀតផង។ គាត់បានប្រាប់ខ្ញុំថាគាត់បានមកប្រទេសកម្ពុជាដំបូងនៅឆ្នាំ១៩៩០ ហើយបន្ទាប់មកគាត់តែងមកទស្សនាជាញឹកញាប់។

បន្ទាប់ពីបានជួបជាមួយស្តេហ្វិននៅពពិលមក ខ្ញុំបានតែងមកទស្សនាវិចិត្រសាលនេះនៅរាល់ពេលបើកពិព័រណ៍ថ្មីៗ និងកម្មវិធីផ្សេងៗ។ ខ្ញុំបានដឹងអំពីបំណងរបស់ស្តេហ្វិនក្នុងការចង់បើកថ្នាក់បង្រៀនថតរូបព្រោះគាត់យល់ថាគេពុំទាន់ស្គាល់និងនិយមវិស័យថតរូបខ្លាំងនៅឡើយទេនៅកម្ពុជា ហើយគាត់ចង់ឃើញមានយុវជនខ្មែរច្រើននាក់ទៀតបញ្ចេញស្នាដៃរូបថតដូចជា វណ្ឌី រតនា ដែរ។ បន្ទាប់ក្រោយមក ទើបខ្ញុំបានដឹងថារតនាគឺជាអ្នកថតរូបដែលរៀនដោយខ្លួនឯង។ វិស័យសិក្សាអប់រំផ្នែកសិល្បៈនៅកម្ពុជានាពេលនោះ( និងមួយផ្នែកធំនៅតែ) មានកម្រិតតិចតួចនៅឡើយ។ នៅទូទាំងប្រទេសមានតែសាកលវិទ្យាល័យសិល្បៈតែមួយគត់គឺសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ នៅក្នុងសាកលវិទ្យាល័យ (កាលនោះនិងឥឡូវ)មានមហាវិទ្យាល័យ៥ ៖ មហាវិទ្យាល័យបុរាណវិទ្យា មហាវិទ្យាល័យស្ថាបត្យកម្ម និងនគររោបនីយវិទ្យា មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យតូរ្យតន្ត្រី និងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ។ គឺមហាវិទ្យាល័យសិល្បៈសូនរូបដែលផ្តោតលើផ្នែក

សិល្បៈចក្ខុទស្សន៍ (visual art) ហើយដែលការសិក្សាថតរូបត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាជាដំបូងនៅឆ្នាំ១៩៩៣ ដោយអ្នកថតរូបនិងអ្នកបោះពុម្ពជនជាតិបារាំងប្រចាំនៅកម្ពុជាឈ្មោះ ធារី ឌីវ៉ូ (Thierry Diwo)។ សាស្ត្រាចារ្យ ច័ន្ទ វិត្ថារិទ្ធ ដែលបង្រៀនជំនាញគំនូរក៏បានបន្តបង្រៀនថតរូបតាំងពីឆ្នាំ១៩៩៥ មកប៉ុន្តែការបង្រៀនមិនមានដំណើរការជាប់ស្ថិតស្ថេរនោះទេដោយសារកង្វះថវិកាផ្គត់ផ្គង់។ នៅឯមហាវិទ្យាល័យសិល្បៈសូនរូបការថតរូបគឺជាការសិក្សាបន្ទាប់បន្សំ ហើយគ្រាន់តែជាឧបករណ៍ជំនួយក្នុងការថតរូបឯកសារសម្រាប់ការងារគំនូរ និងចម្លាក់។ ក្រៅពីសាកលវិទ្យាល័យការថតរូបរបស់ខ្មែរកាលនោះភាគច្រើន គឺជាការងារបែបកាសែត និងផ្សព្វផ្សាយសាធារណៈ (ក្រៅពីរូបថតបែបពាណិជ្ជកម្ម និងគ្រួសារ)។

នៅដើមឆ្នាំ២០០៦ ស្ទេហ្វិនបានប្រមូលថវិកាគ្រប់គ្រាន់ដើម្បីទិញម៉ាស៊ីនបញ្ចាំងមួយ និងទទួលការឧបត្ថម្ភហ្វីលនិងផ្តិតរូបពីសំណាក់ក្រុមហ៊ុនផ្តិតរូបមួយ ហើយក៏សម្រេចបានបើកថ្នាក់បង្រៀនថតរូប ដែលប្រហែលជាថ្នាក់បង្រៀនថតរូបបែបសហសម័យ (contemporary)[២] លើកទីមួយនៅកម្ពុជា។ សិស្សដែលចូលរៀនក៏បានចូលរួមបង់ថវិកាទៅតាមលទ្ធភាព។ មានសិស្សប្រមាណជិត២០នាក់ ដែលក្នុងនោះមានសិស្សស្រី២នាក់ ហើយក្នុងចំណោមសិស្សទាំងអស់ ភាគច្រើនជាសិស្សមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលស្ទេហ្វិនមានទំនាក់ទំនងជាមួយពីមុនមក។ ប្រហែលជា២-៣ខែក្រោយមក ទើបខ្ញុំបានចូលរៀនក្នុងថ្នាក់ថតរូបនេះ បន្ទាប់ពីខ្ញុំបានឃើញការបង្រៀន និងយល់ថាខ្ញុំនៅមានការយល់ដឹងតិចតួចណាស់អំពីការថតរូប។

យើងតែងជួបជុំគ្នាជារៀងរាល់ល្ងាចចុងសប្តាហ៍នៅពពិល ដោយប្រើវិចិត្រសាលជាថ្នាក់រៀន។ ការបង្រៀនរបស់ស្ទេហ្វិនរួមមានមេរៀនបច្ចេកទេស (ពន្លឺ ពណ៌ ការរៀបចំប្លង់ និងនេត្រាទស្សន៍) និងលំហាត់ថតរូបជាក់ស្តែង។ គាត់បានណែនាំអំពីប្រវត្តិនៃការបង្កើតរូបថត និងបច្ចេកទេសថតរូបកាលពីដើម។ យើងបានរៀនបង្កើតនិងផ្តិតរូបថតដោយប្រើក្រដាសរូបថតនិងពន្លឺនៅក្នុងបន្ទប់ងងឹត ក៏ដូចជាបង្កើតម៉ាស៊ីនថតរូបធ្វើពីប្រអប់ក្រដាសនិងរន្ធម្ជុល។ ស្ទេហ្វិនបានបង្ហាញយើងអំពីរបៀបពង្រីកនិងផ្តិតរូប និងរបៀបប្រើម៉ាស៊ីនថតរូបប្រើហ្វីល។ គាត់បានបង្ហាញស្នាដៃរូបថតរបស់អ្នកថតរូបល្បីៗរួមទាំងស្នាដៃរបស់ ហ៊ែនរី ការតៀ-ប្រេស្សុង (Henri Cartier-Bresson)។ គាត់បានលើកទឹកចិត្តឲ្យយើងរៀនពីអ្នកថតរូបខ្មែរឯទៀតដែររួមទាំង វណ្ណឌី រតនា ដែលពេលនោះបានដាក់តាំងពិព័រណ៍ទោលជាលើកដំបូងនៅពពិល មានចំណងជើងថា ក្រឡេកមើលក្នុងការិយាល័យខ្ញុំ *(Looking In My Office)*។ រតនាបានចែករំលែកការរៀនថតរូបដោយខ្លួនឯងរបស់គាត់ និងដំណើរការនៃការបង្កើតស្នាដៃកំពុងតាំងក្នុងពិព័រណ៍នោះ ដែលគាត់បានថតអំពីសកម្មភាពប្រចាំថ្ងៃ

[២] នៅមិនទាន់មានការឯកភាពជាផ្លូវការនៅឡើយទេចំពោះពាក្យខ្មែរសម្រាប់ contemporary art។ ប៉ុន្តែក្នុងរង្វង់សិល្បករ គេបានប្រើប្រាស់ពាក្យ "សិល្បៈសហសម័យ" ជាញឹកញាប់សម្រាប់សំដៅលើ contemporary art ដែលមានន័យថាជាសិល្បៈថ្មីៗដែលបង្កើតឡើងក្នុងសម័យបច្ចុប្បន្ន។ តែពាក្យនេះនៅមិនទាន់មានសុក្រិតភាពនៅឡើយខណៈពេលដែលពាក្យ contemporary art ជាភាសាអង់គ្លេសក៏មានការពិភាក្សាវែកញែកដែរ។ សម្រាប់អត្ថបទនេះ ខ្ញុំប្រើពាក្យ "សហសម័យ" សម្រាប់សំដៅលើ contemporary។

របស់មិត្តរួមការងាររបស់គាត់និងទិដ្ឋភាពនៅខាងក្នុងក្រុមហ៊ុនទូរគមនាគមន៍មួយដែលគាត់បម្រើការឲ្យ។ រតនា និងភាពស្មោះត្រង់ និងល្អិតល្អន់នៅក្នុងស្នាដៃរូបថតរបស់គាត់ធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះ គឺមិនមែនដោយសារមនុស្សនៅក្នុងរូបថតមិនដឹងពីវត្តមានរបស់គាត់នៅពេលថតរូបនោះទេ តែគឺពួកគេហាក់ដូចជាមិនខ្វល់ពីវត្តមានរបស់គាត់ និងម៉ាស៊ីនថតរូបរបស់គាត់។

យើងក៏បានរៀនផងដែរពីការពិនិត្យមើលរូបថត គឺអំពីធាតុនានានៅក្នុងរូបថត ដែលផ្គុំគ្នាផ្តល់ជាអត្ថន័យ។ យើងបានធ្វើដំណើរជាក្រុមទៅសៀមរាបដើម្បីទស្សនាមហោស្រពរូបថតអង្គរលើកទី២ ដែលមហោស្រពនេះជាមហោស្រពរូបថតលើកទី១នៅកម្ពុជាដោយផ្តោតលើរូបថតបែបឯកសារ។បន្ទាប់មកយើងបានរៀនបង្កើតជាកម្រងរូបថតដោយប្រើប្រាស់រូបថតជាច្រើនដែលបំពេញគ្នាចងក្រងជាប្រធានបទមួយដើម្បីប្រាប់ពីសាច់រឿងអ្វីមួយ។ បន្ទាប់ពីបានរៀនអំពីមូលដ្ឋាននិងក្បួនសំខាន់ៗរួចមក ស្ទេហ្វិនបានជំរុញឲ្យយើងថតរូបបែបថ្មីនិងប្លែក។ រាល់ពេលជាច្រើនដែលយើងបានយកការងាររូបថតមកបង្ហាញគាត់ គាត់តែងថាគាត់បានឃើញរូបថតបែបនេះច្រើនដងរាប់មិនអស់រួចមកហើយ និងឲ្យយើងបង្ហាញគាត់អ្វីដែលថ្មី។ ស្ទេហ្វិនបានស្នើឲ្យយើងធ្វើលំហាត់ថតរូបមួយដែលមានប្រធានបទ"ចម្លែក" ដែលគាត់ពន្យល់ថាជាអ្វីក៏ដោយឲ្យតែប្លែកដែលយើងជាធម្មតាមិនដែលធ្វើដូចជា សាកល្បងជាមួយមុំឬប្លង់ថតថ្មីអ្វីក៏បានឲ្យតែមានអារម្មណ៍ថាចម្លែក។ ឧទាហរណ៍មានសិស្សម្នាក់ថតរូបតាមទឹកនៃសំយាបដំបូលផ្ទះ ម្នាក់ទៀតសាកល្បងជាមួយនឹងពន្លឺនិងស្រមោលខ្លួនគាត់ ចំណែកឯម្នាក់ទៀតសាកល្បងជាមួយម៉ាស៊ីនថតរូបរន្ធម្ជុល ដើម្បីបង្កើតរូបថតអំពីអគារទីក្រុងដែលមើលទៅហាក់ដូចជារូបសខ្មៅចាស់ៗ។ គឺលំហាត់ចម្លែកនេះហើយ ដែលបាននាំឲ្យសិស្សទាំងអស់អភិវឌ្ឍទៅជាស្នាដៃចុងក្រោយសម្រាប់ពេលបញ្ចប់វគ្គសិក្សាបន្ទាប់ពីបានរៀនអស់រយៈពេលមួយឆ្នាំមក។

នៅក្នុងឆ្នាំ២០០៧ សិស្សចំនួន១៤នាក់រួមទាំងខ្ញុំដែរបានបញ្ចប់វគ្គថតរូបពីពពិល ហើយបានរៀបចំជាពិព័រណ៍រូបថតជាក្រុមមួយយ៉ាងធំមានចំណងជើងថា"១៤+១"នៅឯវិទ្យាស្ថានបារាំង។ជាការគួរឲ្យសោកស្តាយពេលនោះក៏ជាពេលដែលស្ទេហ្វិនសម្រេចចិត្តបិទពពិលនិងទៅរស់នៅសហរដ្ឋអាមេរិក។សិស្សជាច្រើននាក់បានមានចំណាប់អារម្មណ៍ចង់បន្តការអនុវត្តន៍ថតរូបតទៅទៀតប៉ុន្តែមិនប្រាកដថាត្រូវធ្វើបែបណារួមទាំងខ្ញុំដែរ (ពេលនោះខ្ញុំមានការងារពេញម៉ោងរួចទៅហើយ)។ គឺរតនា ដែលពេលនោះបានមកជួបយើងនិងផ្តល់យោបល់ថាយើងគួរចងក្រងបង្កើតជាក្រុម។ ដោយយល់ឃើញថា រតនាជារៀមច្បងដែលយើងគោរពសរសើរ សិស្សមួយចំនួនដែលបាន បញ្ចប់វគ្គថតរូបជាមួយគ្នា បានសម្រេចចិត្តរួមគ្នាជាក្រុម ហើយនៅក្នុងឆ្នាំដដែលបានបង្កើតជាក្រុមមួយឈ្មោះថា"ស្ទាវសិល្បៈ"។សមាជិកដំបូងនៅពេលនោះមានចំនួន៦នាក់៖ ហេង វ៉ាវុធ ខ្វៃ សំណាង គង់ វល័ក្ខ លីម សុខចាន់ លីណា និងខ្ញុំ ដែលមកពីពពិលព្រមទាំង រតនា ដែលបន្ទាប់មកជាអ្នកដែលយើងបានបោះឆ្នោតជ្រើសរើសជាប្រធានក្រុម។ រតនាបានដឹកនាំក្រុមក្នុងនាមជានាយក តែការសម្រេចចិត្តទាំងអស់ត្រូវបានធ្វើឡើងតាមរយៈការបោះឆ្នោតពីសំណាក់សមាជិកក្រុមទាំងអស់គ្នា។សមាជិកក្រុមទាំងអស់ក៏បានក្លាយជាមិត្តភ័ក្តិ និងមិត្តរួមការងារដ៏ជិតស្និទ្ធ។

ពាក្យ ស្ទាវ មានន័យថាក្មេង ហើយច្រើនប្រើចំពោះសត្វ ជាពិសេសសត្វគោឈ្មោលពេញវ័យបន្ត

ពូជ។ ស្ទាវ ពេលនោះក៏ត្រូវបានប្រើប្រាស់នៅក្នុងភាសានិយាយសាមញ្ញដែរ ដោយសំដៅដល់យុវជនក្មេងៗទាំងប្រុសនិងស្រីដែលច្រើនតែបង្កបញ្ហាក្នុងសង្គម។ពាក្យ ស្ទាវនេះកាលនោះមានប្រជាប្រិយភាពណាស់នៅក្នុងភាសាសារព័ត៌មានសំដៅដល់យុវជនដែលបង្កសកម្មភាពមិនប្រក្រតីនានា។ ហេតុដូច្នេះ នៅពេលពាក្យនេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរបស់យើងមានការប្រឆាំងយ៉ាងខ្លាំងពីសំណាក់សមាជិកក្រុម ដោយយើងជាច្រើននាក់បានគិតថាវាជាពាក្យមិនមានការគោរពនិងឲ្យតម្លៃ។ ប៉ុន្តែយើងបានគិតដែរថាឈ្មោះស្ទាវសិល្បៈក៏មានពាំនាំមកជាមួយនូវន័យថាជាយុវជនជំនាន់ថ្មី ដែលបះបោរដើម្បីសម្ដែង និងឯករាជ្យភាពនៅក្នុងសិល្បៈ។ ដូច្នេះជាចុងក្រោយ យើងក៏សម្រេចចិត្តព្រមព្រៀងគ្នាដាក់ឈ្មោះក្រុមថា "ស្ទាវសិល្បៈ"។

សមាជិកទាំង ៦ នាក់នៅក្នុងក្រុម មានសាវតារនិងការសិក្សាដោយឡែកៗពីគ្នា។ វ៉ារុធ សំណាង និងវល័ក្ខបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដោយវ៉ារុធ និងសំណាងបញ្ចប់ផ្នែកគំនូរ រីឯវល័ក្ខបញ្ចប់ផ្នែកចម្លាក់។ លីណាបានចាប់ផ្ដើមរៀនផ្នែកសេដ្ឋកិច្ច។ រតនាបានទើបចាកចេញពីក្រុមហ៊ុនទូរគមនាគមន៍ ហើយបន្តធ្វើការងារថតរូបតាមរយៈគម្រោងឯករាជ្យ និងគម្រោងផ្ដល់ប្រាក់កម្រៃនានា។ រតនាក៏បានបន្តនូវការសិក្សាដោយខ្លួនឯងជាបណ្ដើរៗនិងបង្កើនចំណាប់អារម្មណ៍លើផ្នែកភាពយន្តនិងទស្សនវិជ្ជា។ ខ្ញុំបានបញ្ចប់ការសិក្សាផ្នែកព័ត៌មានវិទ្យាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកំពុងបំពេញការងារជាមួយអង្គការក្រៅរដ្ឋាភិបាលមួយក្នុងតួនាទីសម្របសម្រួលផ្នែកថតរូប និងទំនាក់ទំនងសាធារណៈ។

កាលនោះយើងបានគិតថាប្រសិនបើយើងនៅជាមួយគ្នា យើងអាចបន្តធ្វើការងារសិល្បៈជាមួយគ្នា រៀនជាមួយគ្នា និងរីកចម្រើនជាមួយគ្នា។ កាលនោះ រតនាជឿថាការនៅជាមួយគ្នាជាក្រុម នឹងអាចឲ្យយើងរក្សាសកម្មភាពនិងផ្ដុំគំនិតគ្នាដើម្បីបង្កើតជាអ្វីមួយថ្មី។ គោលដៅរបស់យើងគឺចង់បង្កើតនូវរចនាសម្ព័ន្ធសិល្បៈឯករាជ្យខ្មែរមួយ ប៉ុន្តែក្នុងទម្រង់បែបណានោះជាអ្វីដែលយើងនៅបន្តស្វែងរក។ យើងបានចាប់ផ្ដើមពីការជួបជុំគ្នាសាមញ្ញនៅតាមផ្ទះរបស់យើង និងផ្ទះរបស់មិត្តភ័ក្តមួយចំនួនជាចម្បង ដើម្បីចែករំលែកចំណេះដឹង និងរៀនអំពីសិល្បៈទាំងអស់គ្នា។ យើងបានមើលខ្សែ ភាពយន្តដោយអ្នកដឹកនាំល្បីៗ និងបញ្ចាំងរូបថតរបស់អ្នកថតរូបអន្តរជាតិនានា។ យើងបានធ្វើដំណើរទៅថតរូបអំពីព្រឹត្តិការណ៍ផ្សេងៗ បន្ទាប់មកមើលរូបថតទាំងនោះជាមួយគ្នា និងពិភាក្សាឲ្យយោបល់គ្នា។ យើងបានអញ្ជើញអ្នកថតរូបអាជីពមួយចំនួនដូចជា ម៉ក់ រ៉េមីស្សា និង អ្នកថតរបស់ទីភ្នាក់ងារ Magnum ប្រចាំនៅភ្នំពេញ ចន វីង (John Vink) ឲ្យចែករំលែកបទពិសោធន៍ការងាររបស់គាត់។ យើងបានជួយគ្នាទៅវិញទៅមកក្នុងការសម្រេចស្នាដៃរបស់យើងរៀងៗខ្លួន ហើយនេះបានក្លាយជាការអនុវត្តន៍ជាប្រចាំរបស់សមាជិកក្រុម។ ឧទាហរណ៍ លីណាជាញឹកញាប់ជួយថតការងារបែបសម្ដែងរបស់សំណាង ហើយសំណាងក៏ជួយលីណាវិញដែរ។ លីណានិងសំណាងបានជួយរតនាក្នុងគម្រោងថតរូបរបស់គាត់។ វ៉ារុធ និងវល័ក្ខតែងជួយគ្នាទៅវិញទៅមកជាដើម។

ការថតរូបបែបឯកសារ និងការដកស្រង់ភាពពិតនៅក្នុងស្រុក គឺជាការងារដ៏ចម្បងរបស់ក្រុមយើងចាប់តាំងពីដំបូងមកម្ល៉េះ។ យើងត្រូវបានជុំរុញចិត្តដោយរតនាដែលគាត់នៅពេលនោះមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការចងក្រងបណ្ណសារចក្ខុអំពីប្រវត្តិបច្ចុប្បន្នរបស់ខ្មែរ។ ការថតរូបនៅពេលនោះគឺភាគច្រើនត្រូវ

*បានអនុវត្តដោយជនជាតិបរទេស ដូច្នេះយើងមានទស្សនៈចង់មានកម្មសិទ្ធក្នុងការចងក្រងសំណេររូបភាពអំពីកម្ពុជា។ ដោយមានអ្នកថតរូបបែបឯកសារ ចន វីង ជាអ្នកផ្តល់ដំបូន្មាន រតនាក៏បានបន្តចាប់យកឱកាសដកស្រង់រូបភាពសង្គមកម្ពុជាជាច្រើន  ពីព្រោះគាត់ពេលនោះមិនសប្បាយចិត្តចំពោះកង្វះខាតកំណត់ត្រាឯកសារអំពីវប្បធម៌របស់គាត់ ពីព្រោះសម្ភារៈជាច្រើនពន់ពេកត្រូវបានបាត់បង់អស់ក្នុងជំនាន់ខ្មែរក្រហម១៩៧៥-៧៩។ខ្ញុំបានចាំថាគាត់ធ្លាប់បានរំឭកយើងថា"យើងត្រូវថតទុកជាឯកសារពីព្រោះវានឹងអាចបាត់បង់ឆាប់ៗ"។ លើសពីនេះ លីណាដែលបានកំពុងសិក្សាផ្នែកសេដ្ឋកិច្ចមានបំណងចង់ប្រើប្រាស់រូបថតដើម្បីបង្ហាញទស្សនៈពីខាងក្នុង។ គាត់បាននិយាយថា "ខ្ញុំចង់បង្ហាញរូបថតខ្មែរដោយជនជាតិខ្មែរ។ ពីព្រោះក្នុងនាមជាអ្នកក្នុងស្រុក យើងអាចផ្តល់នូវទស្សនៈអំពីសង្គមរបស់យើងចេញពីខាងក្នុង"។ ចំពោះខ្ញុំវិញ ខ្ញុំចាប់អារម្មណ៍រូបថតសម្រាប់ជាមធ្យោបាយដើម្បីបង្ហាញពីភាពអយុត្តិធម៌សង្គម។*

*អមជាមួយនឹងការងារបែបឯកសារសមាជិកស្ទាវសិល្បៈខ្លះដែលបានចេញពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនិងដែលបានអនុវត្តជាមួយសម្ភារៈផ្សេងរួចមកហើយបានប្រើប្រាស់ការថតរូបដើម្បីពង្រីកបន្ថែមក្នុងការងារសិល្បៈរបស់គេ។ឧទាហរណ៍វ៉ាវុធដែលមានជំនាញខាងគំនូរស្រាប់បានថតរូបខ្លួនឯងជាការកត់ត្រានូវរាងកាយនិងអារម្មណ៍ ហើយរូបថតនោះមើលទៅហាក់ដូចជារូបគំនូរ។ ចំណែកឯសំណាង ដែលមានជំនាញខាងគំនូរដែរនោះបានប្រើប្រាស់ការថតរូបជាវិធីសាស្ត្រក្នុងការរៀបចំបង្វង់រូបប្រើប្រាស់ពណ៌និងតាក់តែងឆាកយ៉ាងប្រុងប្រយ៉ាត់ក្នុងផ្ទាំងរូបថតហាក់ដូចជាវាត្រូវបានគូរនៅលើផ្ទាំងគំនូរដូច្នោះដែរ។ដោយឡែកវល័ក្ខដែលមានជំនាញខាងចម្លាក់បានថតរូបពីអគារនានាក្នុងក្រុងក្នុងបែបម៉្យាង  ដែលមើលទៅហាក់បីដូចជារូបគំនូរសខ្មៅ។ ប្រហែលជាមកពីចម្រុះភាពនៃការអនុវត្តន៍សិល្បៈនិងចំណាប់អារម្មណ៍របស់សមាជិកក្រុមនេះហើយ ដែលផ្តល់ជាថាមពល និង ជំរុញទឹកចិត្តដល់ក្រុមយើង។*

*នៅទីក្រុងភ្នំពេញពេលនោះ មានវិចិត្រសាលនិងទីសិល្បៈជាច្រើន ដែលគ្រប់គ្រងដោយជនជាតិបរទេស ដូច្នេះក្តីសុបិនដំបូងរបស់យើងគឺចង់មានទីសិល្បៈមួយរបស់យើងផ្ទាល់ ហើយមិនចាំបាច់ចូលរួមក្នុងការដាក់ពាក្យនិងការជ្រើសរើសដោយទីសិល្បៈរបស់គេនានា។ យើងធ្លាប់បានដាក់សំណើពិព័រណ៍ក្រុមស្ទាវសិល្បៈទៅកាន់ស្ថាប័នមួយតែយើងមិនដែលឮការឆ្លើយតបអ្វីសោះ។ប្រហែលជាស្នាដៃការងាររបស់យើងកាលនោះនៅមិនទាន់រឹងមាំមែនប៉ុន្តែវាច្បាស់ណាស់ថាបញ្ហាអំណាចគឺកំពុងស្ថិតនៅពីមុខយើង ហើយយើងមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការពឹងផ្អែកលើជំនួយបរទេសក្នុងស្រុក។  ហេតុដូច្នេះហើយ ក្រុមយើងមានបំណងយ៉ាងមុតមាំចង់ឲ្យមានវិចិត្រសាលមួយដែលគ្រប់គ្រង និងដំណើរការដោយខ្មែរផ្ទាល់ និងមានឯករាជ្យភាពក្នុងការបង្ហាញស្នាដៃរបស់សមាជិកក្រុមយើង។ ក្តីសុបិនរបស់យើងបានក្លាយជាការពិត នៅពេលភោជនីយដ្ឋានថ្មីមួយឈ្មោះបៃតងនៅលើបណ្តោយផ្លូវ៣៦០បានចាប់បើកនៅក្នុងឆ្នាំ២០០៩។បៃតងគឺជាពាណិជ្ជកម្មរួមគ្នាមួយរវាងជនជាតិខ្មែរម្នាក់ និងជនជាតិបរទេសម្នាក់ ដែលចង់ឃើញភោជនីយដ្ឋាននេះជាកន្លែងមួយរាក់ទាក់សម្រាប់សហគមន៍ដើម្បីពិភាក្សាគ្នានិងចែករំលែកគំនិតថ្មីៗ។ភោជនីយដ្ឋាននេះមានលក់ម្ហូបអាហារខ្មែរនិងអាស៊ីក្នុងតម្លៃសមរម្យ និងមានបន្ទប់ប្រជុំសម្រាប់ជួលក្នុងតម្លៃយ៉ាងថោក ឬដោយឥតគិតថ្លៃ។ រតនា*

បានពិភាក្សាជាមួយនឹងម្ចាស់ភោជនីយដ្ឋាន ហើយជាលទ្ធផលគេបានផ្តល់ទីតាំងនៅចំហៀងភោជនីយដ្ឋានឲ្យយើងប្រើជាវិចិត្រសាលរូបថត ដោយមិនគិតថ្លៃជួលសម្រាប់១ឆ្នាំដំបូង។

យើងបានសម្ពោធវិចិត្រសាលស-សដែលជាវិចិត្រសាលដំណើរការដោយសិល្បករនៅភ្នំពេញក្នុងឆ្នាំ២០០៩។ស-សគឺជាពាក្យកាត់ពីឈ្មោះរបស់ក្រុមស្ទាវសិល្បៈ។ពិព័រណ៍ដំបូងរបស់ស-សគឺជាពិព័រណ៍ជាក្រុមនៃស្នាដៃរបស់សមាជិក៥នាក់ក្នុងចំណោមស្ថាបនិករបស់ស្ទាវសិល្បៈ។ក្នុងពេលនោះខ្ញុំកំពុងបំពេញការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកអភិវឌ្ឍន៍អន្តរជាតិនៅទីក្រុងម៉ែលប៊ន ក្រោមអាហារូបករណ៍របស់រដ្ឋាភិបាលអូស្ត្រាលី។ ខ្ញុំបានជ្រើសរើសផ្នែកសិក្សានេះ ព្រោះខ្ញុំចង់ស្វែងយល់អំពីការងារអភិវឌ្ឍន៍សម្រាប់ប្រទេសដែលធ្លាប់មានវិបត្តិសង្គ្រាមដូចជាប្រទេសកម្ពុជានេះ។ បន្ទាប់ពីអស់មួយរយៈនៃការបង្ហាញស្នាដៃរបស់សមាជិកក្រុមស្ទាវសិល្បៈរួចមក យើងយល់ឃើញថាវិចិត្រសាលនេះមិនមែនតែសម្រាប់ក្រុមយើងប៉ុណ្ណោះទេ តែជាចាំបាច់ក៏សម្រាប់សិល្បករខ្មែរឯទៀតដែរ។ ដូច្នេះហើយ យើងបានអញ្ជើញសិល្បករខ្មែរក្មេងៗឯទៀតឲ្យដាក់បង្ហាញស្នាដៃនៅក្នុងវិចិត្រសាលដ៏តូចរបស់យើង។ យើងបានស្វែងរកសិល្បករទាំងនោះតាមរយៈមិត្តភ័ក្តនៅក្នុងរង្វង់សិល្បៈ និងសម្រេចចិត្តជ្រើសរើសសិល្បករដោយការបោះឆ្នោតក្នុងក្រុម។ យើងមានចំណាប់អារម្មណ៍ចំពោះសិល្បករណាដែលបង្ហាញពីការយកចិត្តទុកដាក់ និងតស៊ូប្រឡូកក្នុងការងារបង្កើតស្នាដៃសិល្បៈ និងស្នាដៃណាដែលថ្មីនិងចូលរួមចំណែកក្នុងការអនុវត្តន៍ការងារសិល្បៈសហសម័យ។ យើងបានរៀបចំពីពិព័រណ៍មួយទៅពិព័រណ៍មួយទៀតតាមរយៈថវិកាផ្ទាល់ខ្លួនផងនិងការឧបត្ថម្ភពីមិត្តភ័ក្តនិងអ្នកគាំទ្រវិស័យសិល្បៈផង។

នៅក្នុងឆ្នាំ ២០១០ ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយមិនយូរប៉ុន្មាន វតនាបានផ្លាស់ប្តូរទីលំនៅទៅរស់នៅប្រទេសបារាំងជាមួយគូរដណ្តឹងគាត់។ វតនាបានស្នើឲ្យមានការជ្រើសរើសប្រធានដឹកនាំសម្រាប់ឆ្នាំថ្មី។សមាជិកក្រុមបានបោះឆ្នោតឲ្យខ្ញុំធ្វើជានាយកថ្មី។ដោយសារខ្ញុំមានបទពិសោធន៍ខាងទំនាក់ទំនង ខ្ញុំបានធ្វើការជាមួយក្រុមដើម្បីរៀបចំទម្រង់ជាផ្លូវការនូវផ្លាកសញ្ញាវិចិត្រសាល វិបសាយត៍ និងទំនាក់ទំនងសាធារណៈ។ខ្ញុំបានចាប់ផ្តើមធ្វើការជាមួយអេរិនឃ្លីសិន(Erin Gleeson)ក្នុងនាមជាអ្នកផ្តល់ប្រឹក្សាផ្នែករៀបចំពិព័រណ៍សិល្បៈដល់ខ្ញុំ។ អេរិនបានរស់នៅក្នុងប្រទេសកម្ពុជាជាច្រើនឆ្នាំហើយ ហើយគាត់គឺជាគ្រូបង្រៀនប្រវត្តិសិល្បៈដល់វតនា។គាត់ពេលនោះក៏កំពុងដំណើរការគម្រោងសិល្បៈបាសាក់ដែលជាគម្រោងសាកល្បងក្នុងការផ្តល់ស្ទូឌីយ៉ូធ្វើការនិងសម្ភារៈសិល្បៈដល់សិល្បករ ព្រមទាំងការងាររៀបចំពិព័រណ៍សិល្បៈមួយចំនួនទៀត។មកដល់ពេលនោះ ភោជនីយដ្ឋានបៃតងបានចាប់ផ្តើមគិតថ្លៃជួលទីតាំង។យើងក៏សម្រេចចិត្តប្រមូលថវិកា ដើម្បីបន្តដំណើរការវិចិត្រសាលនិងជាការសំខាន់នោះគឺដើម្បីបង្កើតទីតាំងមួយទៀត ដែលអាចឲ្យយើងធ្វើការងារសិល្បៈផ្សេងៗច្រើនទៀតក្រៅពីពិព័រណ៍។ ក្រោមការសហការគ្នា ជាមួយអេរិន និងភោជនីយដ្ឋានបៃតង យើងបានរៀបចំកម្មវិធីប្រមូលថវិកាមួយ។យើងបានអំពាវនាវដល់សិល្បករនានាក្នុងប្រទេសនិងស្នើឲ្យគេបរិច្ចាគស្នាដៃសិល្បៈសម្រាប់ដាក់ដេញថ្លៃ។ យើងបានទទួលស្នាដៃសិល្បៈចំនួនជាង៦០ ពីសិល្បករខ្មែរនិងបរទេសចំនួន៥៣រូប។ ព្រមជាមួយនឹងការលក់រូបថតរបស់សមាជិកក្រុមស្ទាវសិល្បៈក្នុងតម្លៃពិសេសនិងអាហារពេលល្ងាចយើងប្រមូលថវិកាបានជិត៤០០០ដុល្លាអាមេរិក។វិចិត្រសាលស-សក៏បានបន្តដំណើរការ

ហើយយើងបានបន្តគាំទ្រដល់ការបង្ហាញស្នាដៃរបស់សិល្បករក្មេងៗ ដោយពង្រីកពីការបង្ហាញរូបថតរហូតដល់បង្ហាញស្នាដៃគំនូរ ការតម្លើង (Installation) និងការសម្តែង (Performance)។ ក្នុងរយៈពេលជិត២ឆ្នាំ យើងបានរៀបចំពិព័រណ៍ចំនួន១១ និងបង្ហាញស្នាដៃដោយសិល្បករខ្មែរមកពីភ្នំពេញ និងបាត់ដំបងចំនួនជិត២០នាក់។

ក្នុងអំឡុងពេលកំពុងដំណើរការវិចិត្រសាលសិល្បៈស-ស សំណាងនិងវល័ក្ខក៏កំពុងបម្រើការជាគ្រូបង្រៀនសិល្បៈនៅវិទ្យាល័យនៅឯខេត្តដែរ។ បទពិសោធន៍បង្រៀនសិស្សនៅវិទ្យាល័យធ្វើឲ្យសំណាង និងវល័ក្ខរិតតែយល់ច្បាស់ថាការអប់រំសិល្បៈ គឺនៅមានកម្រិតតិចតួចណាស់ មិនត្រឹមតែចំពោះសិស្សក្នុងសាលាប៉ុណ្ណោះទេ គឺសម្រាប់ក្មេងៗជំនាន់ថ្មីទាំងអស់ផងដែរ។ មានកម្មវិធីបង្រៀនសិល្បៈតែមួយចំនួនប៉ុណ្ណោះនៅទូទាំងប្រទេស។ មានវិទ្យាល័យតែមួយចំនួនប៉ុណ្ណោះដែលមានគ្រូបង្រៀនសិល្បៈ ពីព្រោះរាល់ឆ្នាំមានសិស្សដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈតែមួយចំនួនតូចប៉ុណ្ណោះ ដែលបន្តចាប់យកអាជីពបង្រៀនសិល្បៈ។ ជាច្រើនឆ្នាំកន្លងមក ចំនួនសិស្សដែលបញ្ចប់វគ្គសិក្សាពីមហាវិទ្យាល័យសិល្បៈសូនរូបនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈកាន់តែធ្លាក់ចុះជាលំដាប់។ កាលពីឆ្នាំ២០១២ មានសិស្សផ្នែកគំនូរតែ៤នាក់ប៉ុណ្ណោះ ដែលបានបញ្ចប់និងគ្មានសិស្សផ្នែកចម្លាក់ម្នាក់ទាល់តែសោះ[៣] បើប្រៀបធៀបទៅឆ្នាំ២០០៦ ដែលមានសិស្សផ្នែកគំនូរចំនួន១៧នាក់បានបញ្ចប់និងសិស្សផ្នែកចម្លាក់ចំនួន៧នាក់បានបញ្ចប់[៤]។

ក្នុងរយៈពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅតែជាសាកលវិទ្យាល័យផ្លូវការតែមួយគត់សម្រាប់ការអប់រំផ្នែកសិល្បៈនោះ សាកលវិទ្យាល័យមិនសូវបានរៀបចំកែប្រែកម្មវិធីសិក្សារបស់ខ្លួនអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ សំណាងដែលសិស្សក្នុងជំនាន់ឆ្នាំ២០០៦បានចាំថា ការសិក្សារយៈពេល៤ឆ្នាំរបស់គាត់ គឺស្ទើរតែទាំងស្រុងបានផ្តោតលើបច្ចេកទេសនៃគំនូរ ៖ ខ្សែបន្ទាត់ ការរៀបចំប្លង់ ការប្រើប្រាស់ពណ៌នេត្រាទស្សន៍និងពន្លឺ។ សំណាងបានបញ្ជាក់ថា "ការសិក្សារបស់យើង គឺផ្តោតលើការគូរគំនូរឲ្យបានល្អ[តាមលក្ខណៈបច្ចេកទេស]មិនមែនអំពីការស្វែងរកគំនិតអ្វីនោះទេ"។គាត់បានបន្ថែមថាកត្តាសំខាន់បំផុតគឺត្រូវជាប់ការប្រឡងការពារស្នាដៃនៅមុខគណៈកម្មការ ដែលរួមមានតំណាងមកពីក្រសួងវប្បធម៌និងសាកលវិទ្យាល័យផ្ទាល់។ គាត់បានសារភាពថា "យើងមិនហ៊ានធ្វើការងារដែលមានលក្ខណៈប្រើប្រាស់គំនិតថ្មីៗទេ ពីព្រោះយើងខ្លាចមិនអាចឆ្លើយតបនឹងសំណួររបស់គណៈកម្មការបាន ព្រោះពួកគេចាប់អារម្មណ៍តែបច្ចេកទេសភាព បរិបទ និងស្ថានភាពកាលៈទេសៈនៃរូបគំនូរ"។ គេមិនបានបង្រៀនទ្រឹស្តីសិល្បៈទេ នៅឯសាកលវិទ្យាល័យ។ចំណែកថ្នាក់ប្រវត្តិសិល្បៈវិញគឺគ្រាន់តែមានអំពីប្រវត្តិរចនាបទនៃស្ថាបត្យកម្មខ្មែរប៉ុណ្ណោះ។ តាមរយៈ ព្រហ្ម ពុធវិសាល ដែលជាសិស្សបញ្ចប់ផ្នែកគំនូរក្នុងឆ្នាំ២០១២ ថ្នាក់ប្រវត្តិសិល្បៈគំនូរទើបតែត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាក្នុងពេលថ្មីៗនេះប៉ុណ្ណោះ ហើយថ្នាក់នេះសិក្សាតែអំពីសិល្បករអឺរ៉ុបប៉ុណ្ណោះ។

---

[៣] ពីបទសម្ភាសន៍ជាមួយ ព្រហ្ម ពុធវិសាល ខែកញ្ញា ឆ្នាំ២០១៣។

[៤] ពីបទសម្ភាសន៍ជាមួយ ខ្វៃ សំណាង ខែកញ្ញា ឆ្នាំ២០១៣។

មានបណ្ណាល័យមួយនៅក្នុងសាកលវិទ្យាល័យ ប៉ុន្តែសៀវភៅភាគច្រើនទាក់ទងនឹងគំនូរ និងចម្លាក់ពីអឺរ៉ុបក្នុងអំឡុងសតវត្សរ៍ទី២០ ដែលសៀវភៅទាំងនោះបានពីជំនួយបរិច្ចាគនានា។

ក្រៅពីប្រព័ន្ធសិក្សានៅសាកលវិទ្យាល័យក៏មានកម្មវិធីបណ្តុះបណ្តាលជំនាញសិល្បៈមួយចំនួនទៀតដែរ។ នៅក្រុងភ្នំពេញ វិទ្យាស្ថានរ៉េយំត្រូវបានផ្តួចផ្តើមស្ថាបនាឡើងដោយ លី តាពវុធ និង អាំងគ្រីដ មូអាន់ (Ingrid Muan) នៅឆ្នាំ១៩៩៨ ហើយបានផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេល៤ឆ្នាំលើជំនាញគំនូរ។ រ៉េយំក៏មានកម្មវិធីសិក្ខាសាលាច្នៃប្រឌិតរយៈពេល១ឆ្នាំបន្ថែមទៀត ចំពោះសិស្សដែលចង់បន្តសិក្សាការអនុវត្តន៍សិល្បៈសហសម័យ ដែលនេះប្រហែលជាថ្នាក់រៀនសិល្បៈសហសម័យដំបូងគេបង្អស់នៅក្នុងភ្នំពេញ។ ថ្នាក់ពិសេសនេះមានបង្រៀនអំពីការប្រើប្រាស់ការតម្លើង វីដេអូ និងការសម្តែង ក៏ដូចជាបានសហការជាមួយសិល្បករពីក្រៅប្រទេសមួយចំនួន។ រ៉េយំបានចូលរួមចំណែកយ៉ាងសម្បើមនៅក្នុងការស្រាវជ្រាវនិងបោះពុម្ពផ្សាយសៀវភៅអំពីសិល្បៈនិងវប្បធម៌ខ្មែរ។ ប៉ុន្តែកម្មវិធីអប់រំរបស់វិទ្យាស្ថាននេះបានបញ្ចប់នៅឆ្នាំ២០១០។ ចំណែកឯនៅខេត្តបាត់ដំបងឯណោះវិញ ហ្វារពន្លឺសិល្បៈ ដែលបានចាប់ផ្តើមដំបូងតាំងពីឆ្នាំ១៩៨៦ នៅក្នុងជំរុំសាយធូ (Site 2) នៅព្រំដែនកម្ពុជាថៃបានដំណើរការមណ្ឌលសិល្បៈមួយ ដែលប្រហែលជាមណ្ឌលសិល្បៈដ៏ធំជាងគេបំផុតក្នុងប្រទេស និងបណ្តុះបណ្តាលជំនាញសិល្បៈចក្ខុទស្សន៍ និងសិល្បៈទស្សនីយភាពដល់សិស្សជាច្រើននាក់នៅភាគខាងជើងនៃប្រទេស។

ទោះជាយ៉ាងណាក្តីការអប់រំសិល្បៈនៅក្នុងក្រុងភ្នំពេញមានកម្រិតតិចតួចរីឯឱកាសក្នុងការសាកល្បងនិងការប្រើប្រាស់គំនិតនៅការងារសិល្បៈក៏មិនមានច្រើន។ ដូច្នេះ ស្វាសិល្បៈបានសម្រេចចិត្តជាក្រុមដើម្បីបង្រៀននិងចែករំលែកចំណេះដឹងដែលយើងមានដល់សិស្សក្មេងៗឯទៀត។ នៅក្នុងឆ្នាំ២០១០ សំណាង និង វល័ក្ខបានចាប់ផ្តើមបង្រៀនថ្នាក់គំនូរដោយឥតគិតថ្លៃជារៀងរាល់ថ្ងៃអាទិត្យនៅក្នុងវិចិត្រសាលស-ស។ ថ្នាក់រៀនបានទាក់ទាញសិស្សវិទ្យាល័យនិងអនុវិទ្យាល័យចំនួន១៧នាក់។ បន្ទាប់មកដោយយល់ថាវិចិត្រសាលស-សតូចនិងមានកម្រិតចំពោះកម្មវិធីថ្នាក់គំនូរ និងសកម្មភាពសិល្បៈផ្សេងៗទៀតផង យើងក៏បានពង្រីកទៅបើកទីតាំងថ្មីមួយទៀតហៅថា គម្រោងសិល្បៈស-ស ដែលមានទីតាំងនៅក្នុងអគារប៊ូឌីង លើបណ្តោយមហាវិថីសុធារស។

យើងបានសម្ពោធបើកគម្រោងសិល្បៈស-សនៅក្នុងឆ្នាំ២០១០ដើម្បីជាទីចែករំលែកចំណេះដឹងនិងគាំទ្រដល់សិល្បករឲ្យសម្រេចបាននូវគំនិតថ្មីៗ។ យើងផ្តោតសំខាន់លើការងារសិល្បៈបែបសហការគ្នានិងបែបសាកល្បង។ សម្រាប់យើង ការសាកល្បងមានន័យថាលើកទឹកចិត្តដល់ដំណើរការបង្កើតថ្មី ទាំងគំនិត និងទម្រង់ដែលផ្ទុះបញ្ចាំងពីកាលៈទេសៈបច្ចុប្បន្ន និងដែលអាចជាការពិសោធន៍និងបរាជ័យ ហើយមិនផ្តោតលើការបង្កើតស្នាដៃសម្រេចសម្រាប់ពិព័រណ៍សិល្បៈឡើយ។ ការសហការរបស់យើងទាក់ទងនឹងការងារជាក្រុមរវាងសិល្បករខ្មែរ សិល្បករក្នុងតំបន់អាស៊ី និងនៅប្រទេសផ្សេងៗទៀតក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញក្នុងវិស័យសិល្បៈនានា ដែលគេទាំងអស់ចែករំលែកចំណេះដឹងគ្នា។ យើងបានសាកល្បងវិធីសាស្ត្រផ្សេងៗក្នុងការប្រឡូកជាមួយការងារសិល្បៈឧទាហរណ៍ដូចជាផ្តល់ទីកន្លែងរបស់យើងជាស្ទូឌីយ៉ូសម្រាប់សិល្បករ

ធ្វើការ និវាសដ្ឋានសិល្បៈជាមួយសិស្សបញ្ចប់ពីវិទ្យាស្ថានវៃយំ គង់ ចាន់ណា និងសិល្បករពីរនាក់ទៀតពីមកពីតំបន់អាស៊ីគឺ ម៉ាសារូ អៃវ៉ៃ (Marasu Iwai) និង ជេសាន់ ថូនីញ៉ូវឺន័រ (Jason Tonio Woerner) ក៏ ដូចជាសាកល្បងពិនិត្យមើលសិល្បៈសម្តែងតាមរយៈសិក្ខាសាលាជាមួយសិល្បករសម្តែង ដើងចាស់ជនជាតិជប៉ុន ស៊ីជី ស៊ីមូដា (Seiji Shimoda) និងរៀបចំកម្មវិធីបណ្តុះបណ្តាល Blogging សម្រាប់សិល្បករដែលសម្របសម្រួលដោយអ្នកBloggerកែវគូនីឡាព្រមទាំងរៀបចំកម្មវិធីបាឋកថាដោយសិល្បករខ្មែរនិងបរទេសជាច្រើនទៀត។

វាជាកាសម្រេចចិត្តដ៏ប្រាកដប្រជាមួយរបស់ក្រុមយើងចំពោះការជ្រើសរើសយកអគារប៊ូឌីងជាទីតាំងប្រចាំរបស់គម្រោងសិល្បៈស-ស។ គំនិតនេះត្រូវបានផ្តួចផ្តើមដោយរតនា ដែលធ្លាប់មានបទពិសោធន៍នៅក្នុងសហគមន៍នេះ តាមរយៈគម្រោងការងារថតរូបមួយ[៥]។ បើទោះជាដំបូង យើងមានភាពខ្វាចរអារបន្តិចពីសភាពខាងក្រៅ និងភាពងងឹតនៅក្នុងអគារយ៉ាងណាក្តី ក៏ក្រុមយើងសម្រេចចិត្តបើកទីសិល្បៈថ្មីនៅក្នុងអគារប្រវត្តិសាស្ត្រដ៏សំខាន់នេះនិងនៅជាមួយនឹងសហគមន៍សិល្បករដែលរស់នៅទីនេះស្រាប់។អគារប៊ូឌីងដែលដំបូងជាអគារស្នាក់នៅរបស់សាលាក្រុងត្រូវបានកសាងឡើងនៅទសវត្សរ៍៦០ ដោយស្ថាបត្យករខ្មែរ លូ បានហាប់ និងវិស្វករបារាំង ឡាឌីមៀ បូឌៀនស្គី (Vladimir Bodiansky) ហើយគឺជាផ្នែកមួយនៃគម្រោងមណ្ឌលវប្បធម៌មាត់ទន្លេបាសាក់ (Bassac River Front)[៦]។ អគារប៊ូឌីង គឺជាគំរូសាកល្បងមួយក្នុងការសាងសង់អគារស្នាក់នៅច្រើនជាន់បែបទំនើបដែលមានតម្លៃទាប ជាពិសេសសម្រាប់ដល់សិល្បករ បុគ្គលិកវប្បធម៌ និងបុគ្គលិកសាលាក្រុង។ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងរបបខ្មែរក្រហមអតីត អ្នកស្នាក់នៅក្នុងអគារនេះ ដែលនៅរស់រានបានវិលត្រឡប់មករស់នៅក្នុងអគារនេះវិញបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩។ បច្ចុប្បន្ននេះ អគារប៊ូឌីងគឺជាសហគមន៍ដ៏សម្បូរបែបមួយនៅក្នុងទីក្រុង ដែលមានប្រជាជនប្រមាណជាង២៥០០នាក់ ដោយរួមមានអ្នករបាំ តន្ត្រីករដើងចាស់ អ្នកជំនាញឆ្លាក់ឈើ បុគ្គលិកផ្នែក វប្បធម៌ បុគ្គលិករដ្ឋាភិបាលនិងអ្នកលក់ដូរតាមដងផ្លូវ។ប៉ុន្តែសហគមន៍នេះបានទទួលរងនូវទស្សនៈអវិជ្ជមានពីសំណាក់សាធារណជន ថាជាកន្លែងមិនមានសុវត្ថិភាព គ្មានអនាម័យពោរពេញទៅដោយភាពក្រីក្រ គ្រឿងញៀន និងការរកស៊ីផ្លូវភេទជាដើម។ នៅក្នុងបរិបទនេះ យើងចង់ប្រារព្ធនូវស្ថាបត្យកម្មដ៏សំខាន់នេះ ហើយចូលរួមចំណែកក្នុងការស្តារនូវកេរ្តិ៍ឈ្មោះសហគមន៍សិល្បៈនេះ និងផ្លាស់ប្តូរទស្សនៈអវិជ្ជមាននានា។

ក្រោយមកមិនយូរប៉ុន្មាន យើងយល់ច្បាស់ថាការដំណើរការទីតាំងសិល្បៈទាំងពីរគឺទាំង វិចិត្រសាលសិល្បៈស-សផង និងគម្រោងសិល្បៈស-សផង នឹងមិនជាការប្រសើរបំផុតសម្រាប់ក្រុមឡើយ។ យើងបានទទួលស្គាល់ថា ការងារដំណើរការវិចិត្រសាលសិល្បៈប្រហែលមិនមែនជាការ ប្រើប្រាស់ក៏ប្រសើរបំផុតនូវជំនាញ និងធនធានក៏ដូចជាពេលវេលាដ៏មានកំណត់របស់យើងឡើយ។ ផ្ទុយទៅវិញ បទពិសោធន៍របស់យើងនៅ

---

[៥] វណ្ណី រតនា (ក្រឡេកមើលមកក្នុង *(Looking In)* ២០០៥។

[៦] Darryl Leon Collins and Helen Grant Ross, *Building Cambodia: 'New Khmer Architecture' 1953-1970*, Bangkok: The Key Publisher Ltd., 2006.

ឯគម្រោងសិល្បៈស-សបញ្ជាក់ថា ប្រហែលជាការបណ្ដុះនូវយុវជនច្នៃប្រឌិតជំនាន់ថ្មីតាមរយៈថ្នាក់បង្រៀនសិល្បៈនិងការសហការរវាងក្នុងនិងក្រៅប្រទេសដែលជាអ្វីដែលយើងអាចចូលរួមចំណែកបានប្រសើរបំផុត។ ជាលទ្ធផល យើងបានដំណើរការវិចិត្រសាលសិល្បៈស-សរហូតមកដល់ឆ្នាំ២០១១ ហើយនៅពេលនោះក្រុមស្ទាវសិល្បៈ និងអេរិន ឃ្វីសិន បានរួមបញ្ចូលគ្នារវាងវិចិត្រសាលសិល្បៈស-ស និងគម្រោងសិល្បៈបាសាក់របស់អេរិនដើម្បីបង្កើតជាស-សបាសាក់។ស-សបាសាក់គឺជាវិចត្រិសាលនិងមណ្ឌលធនធានដែលផ្ដោតលើការសម្របសម្រួល និងចែករំលែកវប្បធម៌សិល្បៈចក្ខុទស្សន៍នៅក្នុង និងចេញពីកម្ពុជា ហើយអេរិនបានដឹកនាំទីសិល្បៈនេះតាំងពីពេលនោះមក។ ការផ្លាស់ប្ដូរគោលដៅនេះ អនុញ្ញាតឲ្យក្រុមស្ទាវសិល្បៈផ្ដោតកម្លាំងនិងចំណេះដឹងលើគម្រោងសិល្បៈស-ស ដែលជាទីសិល្បៈបត់បែនសម្រាប់លទ្ធភាពថ្មីៗ។

ក្នុងរយៈពេល៣ឆ្នាំមកនេះ សមាជិកនៃក្រុមស្ទាវសិល្បៈបានផ្លាស់ប្ដូរ ហើយគម្រោងសិល្បៈស-សក៏មានការប្រែប្រួលដែរ។វ៉ាវុធវល័ក្ខនិងរតនាបានសម្រេចចិត្តចាកចេញពីក្រុមដើម្បីបន្តការងារសិល្បៈរបស់គេរៀងៗខ្លួន ចំណែកលីណា សំណាង និងខ្ញុំនៅបន្តដំណើរការគម្រោងនេះតទៅទៀត។ ថ្នាក់បង្រៀនសិល្បៈគឺជាផ្នែកចម្បងមួយនៃកម្មវិធីរបស់យើង។ សំណាង និងលីណាបានបន្តបង្រៀនថ្នាក់សិល្បៈផ្នែកគំនូរចម្លាក់សេរី និងរូបថត ហើយប្រមូលសិស្សថ្មីៗច្រើននាក់ទៀតពីក្នុងប៊ូឌីង។ ថ្នាក់នេះ ដំណើរការតាមបែបការសិក្សាដោយឥតគិតថ្លៃ។ ក្នុងនាមជាគ្រូបង្រៀនសំណាង និងលីណាបរិច្ចាគពេលវេលានិងចែករំលែកចំណេះដឹងចំណែកឯសិស្សៗទទួលរ៉ាប់រងការចំណាយលើសម្ភារៈសិក្សាដោយខ្លួនឯង។ ថ្នាក់នេះបានអភិវឌ្ឍពីការរៀនបច្ចេកទេសគូររូបនិងថតរូបមកជាការស្វែងរកនិងសាកល្បងគំនិតនានាគឺប្រែក្លាយគំនិតមកជាការបង្ហាញបែបចក្ខុ។យើងលើកទឹកចិត្តឲ្យសិស្សទាំងឡាយស្នើឡើងនូវគំនិតរបស់គេហើយគិតថាតើត្រូវប្រើសម្ភារៈណាដើម្បីសម្រេចការបង្ហាញគំនិតនោះ។ សិស្សៗក៏បានចូលរួមរៀនពីកម្មវិធីពិព័រណ៍ និងបាឋកថានានា នៅក្នុងក្រុងភ្នំពេញ។ ពួកគេក៏បានរៀនតាមរយៈការជួយដោយផ្ទាល់ដល់ការងារសិល្បៈរបស់សំណាង និងលីណា។

បើទោះជាមានការផ្លាស់ប្ដូរនៅក្នុងការងាររបស់យើងយ៉ាងណាក្ដីកត្តាចម្បងមួយដែលគម្រោងសិល្បៈស-សព្យាយាមអនុវត្តជានិច្ចនោះគឺ ការសហការរវាងក្នុងនិងក្រៅប្រទេស ដែលមានភាពទាក់ទងសម្រាប់បរិបទជាក់ស្ដែងនៅក្នុងសហគមន៍យើងផ្ទាល់ និងដែលអាចឲ្យមានការចូលរួមដ៏មានអត្ថន័យពីសំណាក់សហគមន៍ដែលយើងធ្វើការជាមួយ។ យើងតែងតែប្រុងប្រយ័ត្នជាប្រចាំថា គំនិតគួរតែផ្ដួចផ្ដើមចេញពីក្នុងសហគមន៍ហើយគេចូលរួមសម្រេចចិត្តតាំងពីចាប់ផ្ដើមរហូតដល់បញ្ចប់គឺតាំងពីការផ្ដើមគំនិតការគ្រោងនិងកសាងនិងរីករាយជាមួយនឹងលទ្ធផលផងដែរ។ ឧទាហរណ៍នៅក្នុងគម្រោងបន្ទប់សម្លេង (២០១១) យើងបានធ្វើការជាមួយតន្ត្រីកររស់នៅប៊ូឌីង ហែម ភិរុណ និងហែម សុគន្ធ សិល្បករសម្លេងនិងការងារសាកល្បង ដេវីឌហ្គាន់ (David Gunn) និងជាងម្នាក់ ដើម្បីសហការគ្នាគ្រោងបង្កើតសម្រេចនិងសាកល្បងប្រើប្រាស់ឧបករណ៍តន្ត្រី និងសម្លេងថ្មីៗនៅក្នុងបន្ទប់គម្រោងសិល្បៈស-ស។ ដោយយោងលើឧបករណ៍តន្ត្រីបុរាណខ្មែរដែលស្ទើរតែបាត់បង់ទៅហើយនោះ យើងជាក្រុមបានប្រែក្លាយបន្ទប់គម្រោងសិល្បៈស-ស ទៅជាការតម្លើងនៃឧបករណ៍តន្ត្រី និងសម្លេង ដែលបង្កើតឡើងពីសម្ភារៈកែច្នៃប្រើជាថ្មីនិងសម្ភារៈឧស្សាហកម្មមួយចំនួន។

បន្ទប់សម្លេង បានបម្រើជាទីសហការសម្តែងឥតព្រៀងទុកមួយ ដែលទស្សនិកជនអាចលេងតន្ត្រីជាក្រុម និងសាកល្បងការសម្តែងឥតព្រៀងទុកជាមួយគ្នា។ យើងបានរៀបចំកម្មវិធីសាធារណៈជាច្រើនជាមួយតន្ត្រីករ និងអ្នករបាំសហសម័យមួយចំនួនក៏ដូចជាកម្មវិធីសម្តែងសហការជាក្រុមបែបសាកល្បងខ្លះទៀត។ យើងក៏បានរៀបចំកម្មវិធីឯកជនសម្រាប់ប្រជាជននៅប៊ូឌីងនិងសិស្សតន្ត្រីមកពីសិល្បៈខ្មែរអមតៈ[៧] ដែលមានទីតាំងនៅជិតនោះ ដើម្បីសាកល្បងប្រើប្រាស់ឧបករណ៍ថ្មីៗនៅក្នុងបន្ទប់សម្លេង។

ដោយបានយល់ថាបទពិសោធន៍នៃគម្រោង បន្ទប់សម្លេង នៅមានកម្រិតព្រោះសកម្មភាពនានាបានកើតឡើងតែនៅក្នុងបន្ទប់សិល្បៈនោះ យើងក៏បានពង្រីកសកម្មភាពដោយរៀបចំព្រឹត្តិការណ៍នានានៅក្រៅបន្ទប់សិល្បៈស-សនៅតាមទីតាំងនានានៃអគារប៊ូឌីងទាំងមូល និងដូច្នេះលប់បំបាត់ព្រំដែនបែងចែករវាងទីសិល្បៈនិងទីសហគមន៍។ ក្នុងគម្រោង រាត្រីពណ៌ស (២០១២) យើងបានលើកទឹកចិត្តសិស្សចំនួន១៤នាក់ឲ្យធ្វើទំនាក់ទំនងជាមួយអ្នកជិតខាងរបស់គេ និងអ្នករស់នៅក្នុងប៊ូឌីងឯទៀត ដើម្បីបង្កើតការងារថ្មី។ សិស្សម្នាក់ៗបានសម្រេចចិត្តធ្វើការលើគំនិត និងប្រធានបទ ដែលគេជ្រើសរើសខ្លួនគេ។ សិស្សខ្លះបានថតរូបអ្នករស់នៅក្នុងប៊ូឌីង ហើយជាតបស្នងបានបង្រៀន ពួកគាត់ឲ្យចេះប្រើម៉ាស៊ីនថត និងឲ្យពួកគាត់ថតរូបឲ្យសិស្សៗវិញ។ សិស្សខ្លះទៀតបានគោះទ្វារអ្នកជិតខាងសុំរបស់នានាដែលគេលែងត្រូវការដើម្បីយកមកបង្កើតជាស្នាដៃចម្លាក់រួមគ្នាមួយ ដែលពួកគេគិតថាអាចផ្តល់គំនិតដល់អគារថ្មីៗទៅអនាគត។ សិស្សទាំងអស់គ្នាបន្ទាប់មកសម្រេចចិត្តពីរបៀបនិងទីតាំងដែលពួកគេចង់បង្ហាញស្នាដៃរបស់គេ។ មានអ្នកខ្លះចង់ដាក់បង្ហាញការងារនៅក្នុងបន្ទប់គម្រោងសិល្បៈស-ស ចំណែកអ្នកខ្លះទៀតចាប់អារម្មណ៍នៅតាមកន្លែងនានានៅក្នុងបរិវេណអគារប៊ូឌីង។ ឧទាហរណ៍ សិស្សម្នាក់បានជ្រើសរើសរៀបចំបង្ហាញរូបថតរបស់ប្រជាជនក្នុងសហគមន៍នេះនៅលើជញ្ជាំងមួយក្រោមជណ្តើរ ដែលអាចឲ្យមនុស្សច្រើនដែលដើរកាត់បានទស្សនា និងអ្នកដែលជាម្ចាស់រូបថតបានយករូបថតរបស់គេពីជញ្ជាំង។ សិស្សម្នាក់ទៀតបានរៀបចំបង្ហាញរូបថតនៅឯហាងកាហ្វេមួយ ដែលម្ចាស់ហាងជាប្រធានបទនៅក្នុងរូបថតទាំងនោះ។ ភោជនីយដ្ឋាននៅមាត់ផ្លូវមួយត្រូវបានប្រែក្លាយទៅជារោងភាពយន្តសហគមន៍ និងបញ្ចាំងការងារ រូបថតផ្សេងៗរបស់សិស្សដល់ភ្ញៀវដែលពិសាអាហារនៅទីនោះ។

លើសពីនេះ ក្រោមការសហការជាមួយសិល្បករសម្តែង និងវីដេអូ ថូបិន រហ្សលីន (Tobin Rothlein) អ្នកបង្កើតខ្សែភាពយន្ត គាំ ច័ន្ទរស្មី និងក្រុមប្រព័ន្ធផ្សព្វផ្សាយប្រចាំនៅអូស្ត្រាលី Big Stories គម្រោងសិល្បៈស-ស បានដំណើរការសិក្ខាសាលាវីដេអូជាមួយសិស្សរបស់យើងនិងក្រុមយុវជនអ្នកសម្របសម្រួលសហគមន៍មួយក្រុមនៅប៊ូឌីងចាប់តាំងពីឆ្នាំ២០១២មក។ លទ្ធផលដែលបានពីសិក្ខាសាលាវីដេអូ រូបថត និងគំនូរចម្លាក់សេរីត្រូវបានបង្ហាញនៅក្នុងពិព័រណ៍ ស្និទ្ធស្នាល នៅក្នុងមហោស្រពយុវជនខ្មែរ ២០១២ ដែលខ្ញុំមានតួនាទីជាអ្នក

---

[៧] សិល្បៈខ្មែរអមតៈគឺជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក។ការិយាល័យក្នុងប្រទេសកម្ពុជាគឺស្ថិតនៅតាមបណ្តោយមហាវិថីសុធារស នៅពីមុខអគារប៊ូឌីង។ សិល្បៈខ្មែរអមតៈមានថ្នាក់បង្រៀនតន្ត្រី និងរបាំនៅក្នុងអគារប៊ូឌីងសម្រាប់សិស្សជំទង់ៗ។

រៀបចំកម្មវិធីសិល្បៈចក្ខុទស្សន៍។ សិស្សទាំងអស់រួមគ្នាជ្រើសរើសចំណងជើង ស្និទ្ធស្នាល ព្រោះវាផ្ទុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេផ្ទាល់។ស្និទ្ធស្នាល មានន័យថាជាទីស្រឡាញ់ជាទីពេញចិត្តស្អិត។ស្និទ្ធជាមួយអ្នកណាម្នាក់មានន័យថាស្រឡាញ់គេអស់ពីចិត្តទុកចិត្តស៊ប់។ ចំពោះសិស្សមួយចំនួនដែលរស់នៅក្រៅបុ៊ូឌីង ពេលបានចូលមកក្នុងបុ៊ូឌីងលើកដំបូងមានអារម្មណ៍មិនសុខស្រួលនិងខ្លាច។ប៉ុន្តែនៅពេលដែលពួកគេបានចំណាយពេលនិងប្រាស្រ័យជាមួយអ្នករស់នៅទីនេះពួកគេបានយល់ឃើញថាសហគមន៍នេះពោរពេញទៅដោយគំនិតច្នៃប្រឌិតចិត្តល្អនិងចេះតស៊ូ។ហេតុដូច្នេះហើយសិស្សទាំងអស់ចង់បង្កើតបទពិសោធន៍ស្និទ្ធស្នាល មួយដល់អ្នកមកទស្សនា។ ពិព័រណ៍ ស្និទ្ធស្នាល ក៏បានកើតឡើងនៅក្នុងបន្ទប់សិល្បៈស-សផង និងនៅជុំវិញបរិវេណបុ៊ូឌីងផង។ លើកនេះសិស្សៗធ្វើការជាមួយសាលារៀនសហគមន៍ ហើយប្រែក្លាយថ្នាក់រៀនឲ្យទៅជាការតម្លើងនៃវីដេអូជាច្រើនដោយគេខ្ចីទូរទស្សន៍មួយចំនួនពីប្រជាជនក្នុងសហគមន៍នេះ។ សិស្សៗក៏សុំចាក់បង្ហាញវីដេអូនៅតាមហាងអ៊ុតសក់ ភោជនីយដ្ឋាន និងហាងគេសដ្ឋៈនានា ដោយប្រើទូរទស្សន៍ដែលមានស្រាប់នៅតាមកន្លែងទាំងនោះ។ សិស្សៗជាថ្មីម្តងទៀតបានកែហាងកាហ្វេទៅជារោងភាពយន្តសហគមន៍ និងបញ្ចាំងខ្សែវីដេអូដែលពួកគេបានបង្កើត។

ការទាក់ទាញទស្សនិកជនខ្មែរ គឺជាគោលដៅរបស់គម្រោងសិល្បៈស-សតាំងពីដើមមកម្ល៉េះ។ ក្នុងរយៈពេលចុងទសវត្សរ៍ចុងក្រោយនេះមានស្ថាប័ននិងទីកន្លែងថ្មីៗសម្រាប់សិល្បៈសហសម័យជាច្រើនដែលជាញឹកញាប់បានទាក់ទាញភាគច្រើនទស្សនិកជនបរទេសនិងពេលថ្មីៗនេះដល់ភ្ញៀវអន្តរជាតិ។កន្លែងដែលបានទាក់ទាញទស្សនិកជនខ្មែរបានយ៉ាងច្រើនសន្ធឹកសន្ធាប់មិនដែលឃើញពីមុនមកនោះគឺវិទ្យាស្ថានវ៉េយ៉ាំ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ សិល្បករខ្មែរបានបង្កើតទីសិល្បៈថ្មីៗនៅក្នុងភ្នំពេញ បាត់ដំបង និងសៀមរាប ចំណែកឯទស្សនិកជនខ្មែរក៏បានកើនឡើងជាលំដាប់។ តែទោះជាយ៉ាងណាក្តី ការទាក់ទាញប្រជាជនខ្មែរសាមញ្ញនៅក្នុងសិល្បៈសហសម័យនៅមានកម្រិតតិចតួចបំផុត។ អ្នកដែលទស្សនាសិល្បៈសហសម័យភាគច្រើនគឺស្ថិតនៅក្នុងរង្វង់សិល្បៈរួចទៅហើយ។ គម្រោង បន្ទប់សម្លេង រាត្រីពណ៌ស និង ស្និទ្ធស្នាល គឺជាផ្នែកមួយនៃកិច្ចខិតខំរបស់គម្រោងសិល្បៈស-សក្នុងការព្យាយាមប្រឡូកនិងស្វែងរកសិល្បៈដែលបង្កើតឡើងក្រោមការសហការជាមួយប្រជាជនខ្មែរសាមញ្ញមានចំណូលទាបដូចជាប្រជាជននៅបុ៊ូឌីងជាដើមគឺបទពិសោធន៍សិល្បៈដែលអាចចូលរួមបាន មានភាពទាក់ទង និងភាពកំសាន្តសម្រាប់គាត់។ យើងព្យាយាមប្រឈមនឹងបញ្ហាអំណាចទាក់ទងនឹងអ្នកដែលអាចបង្កើតស្នាដៃសិល្បៈ និងអ្នកដែលអាចទស្សនានិងចូលរួមក្នុង សិល្បៈ។

តាមរយៈការបង្កើតទីសហគមន៍ និងព្រឹត្តិការណ៍ផ្សេងៗបែបនេះ គម្រោងសិល្បៈស-សចង់បង្កើតនូវបរិយាកាសទូលាយមួយ ដែលសមាជិកសហគមន៍អាចចូលរួមក្នុងគម្រោងបានក្នុងនាមជាខ្លួនគេផ្ទាល់ទាំងស្រុង។ពួកគាត់ចូលរួមជាមួយយើងបង្កើតខ្លឹមសារទម្រង់និងការបង្ហាញស្នាដៃ។គម្រោងសិល្បៈស-សក៏សង្ឃឹមផងដែរថានឹងអាចប្រឈមផ្លាស់ប្តូរទស្សនៈអវិជ្ជមាននានាអំពីបុ៊ូឌីង។ ការងារទាំងនេះរួមមានផ្ទុះបញ្ចាំងអំពីតម្លៃស្ថាបត្យកម្មនៃអគារនេះក៏ដូចជាផ្សារភ្ជាប់ទស្សនិកជននានាក្នុងភ្នំពេញជាមួយនឹងប្រជាជននៅបុ៊ូឌីង។ ព្រឹត្តិការណ៍សាធារណៈដូចជារាត្រីពណ៌ស ឲ្យធ្វើទស្សនិកជននៅក្នុងក្រុងបានរៀនស្វែងយល់អំពីសហគមន៍

ប៊ូឌីងតាមរយៈបទពិសោធន៍ចូលទស្សនាផ្ទាល់ក៏ដូចជាបង្កើតឱកាសសម្រាប់ប្រជាជនក្នុងប៊ូឌីងបង្ហាញដល់ទស្សនិកជនពីខាងក្រៅអំពីស្នាដៃច្នៃប្រឌិតនានាតាមរយៈពិព័រណ៍។ សហគមន៍ និងសិស្ស ទាំងឡាយបង្កើតស្នាដៃសិល្បៈដោយពិនិត្យលើកត្តាប្រឈមដ៏ស្មុគស្មាញនានាដែលពួកគេជួបប្រទះ ប៉ុន្តែក៏បង្ហាញពីតម្លៃនានាដែលពួកគេមានចំពោះសហគមន៍ និងសិល្បៈ។

យើងព្យាយាមកែគំនិតពីសហគមន៍ ដែលមានទីតាំងជាអចិន្ត្រៃយ៍មកជាសហគមន៍សកម្មបណ្ដោះអាសន្នវិញ។ជាចុងក្រោយ អគារប៊ូឌីងត្រូវបានផ្លាស់ប្ដូររូបរាងដ៏គួរឲ្យកត់សម្គាល់ ដោយសារអ្នករស់នៅទីនេះកែប្រែទម្រង់របស់អគារ។ បច្ចុប្បន្ននេះ សហគមន៍នេះស្ថិតនៅក្រោមការគំរាមកំហែងនៃការផ្លាស់លំនៅ និងអគារទាំងមូលអាចនឹងត្រូវវាយកម្ទេច។ គម្រោងសិល្បៈស-ស ទាំងទីតាំងនិងសកម្មភាពរបស់យើងក៏មានការផ្លាស់ប្ដូរយ៉ាងច្រើនតាំងពីយើងបានចាប់ផ្ដើមមក។ជាជាងផ្ដល់នូវទីតាំងអចិន្ត្រៃយ៍សម្រាប់តាំងពិព័រណ៍ យើងធ្វើការជាមួយសិស្សនិងប្រជាជននៅប៊ូឌីង ដើម្បីរៀបចំព្រឹត្តិការណ៍សាធារណៈដែលមានរយៈពេលខ្លីនិងតែងផ្លាស់ប្ដូររូបរាងនៅជុំវិញអគារនេះ។យើងដកបទពិសោធន៍និងតស៊ូមតិសម្រាប់សហគមន៍មួយដែលកើតឡើងពីការច្នៃប្រឌិតរួមគ្នាជាជាងពីទីតាំងអចិន្ត្រៃយ៍។[៨] យើងសង្ឃឹមថាសកម្មភាពជាក្រុមដែលមានលក្ខណៈផ្លាស់ប្ដូរនេះអាចផ្ដល់ជាគំរូមួយក្នុងការទប់ទល់ និងតស៊ូចំពោះអនាគតមិនប្រាកដរបស់សហគមន៍ប៊ូឌីង។ ដោយព្យាយាមលប់បំបាត់ការពឹងផ្អែកលើគម្រោង និងទីតាំងរបស់គម្រោងសិល្បៈស-ស និងជំនួសដោយការច្នៃប្រឌិតប្រើប្រាស់និងប្រែក្លាយទីតាំងរួមក៏ដូចជាទីកន្លែងរស់នៅរបស់ពួកគាត់ឲ្យទៅជាកន្លែងសម្រាប់បង្ហាញនិងចូលរួមនៅក្នុងសិល្បៈ យើងសង្ឃឹមថាប្រជាជននៅទីនេះនឹងអាចក្ដាប់បានក្នុងការទប់ទល់និងតស៊ូជាមួយនឹងព្រឹត្តិការណ៍ផ្លាស់ទីលំនៅចែជន្យទៅអនាគត។គឺមានតែសិស្សសិល្បៈនិងប្រជាជននៅក្នុងសហគមន៍នេះហើយដែលដឹងច្បាស់បំផុតពីបញ្ហារបស់ពួកគេផ្ទាល់ និងដែលអាចប្រើប្រាស់ភាពច្នៃប្រឌិតរួមគ្នារបស់គេបានប្រសើរជាងអ្នកណាទាំងអស់ សម្រាប់ការបញ្ចេញមតិ និងសកម្មភាពជាក្រុម។

សិល្បៈស-ស មិនមែនជាអង្គការក្រៅរដ្ឋាភិបាល (NGO) ទេ។ យើងគឺជាយន្តការ សាកល្បងមួយ។ ដោយសារខ្ញុំមានបទពិសោធន៍ផ្ទាល់ក្នុងវិស័យអភិវឌ្ឍន៍និងការងារអង្គការក្រៅរដ្ឋាភិបាលផង និងដោយសារនៅក្នុងប្រទេសមួយដែលពឹងផ្អែកយ៉ាងធ្ងន់ធ្ងរលើជំនួយបរទេសនិង កម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាល ខ្ញុំមានការប្រយ័ត្នប្រយែងយ៉ាងខ្លាំងចំពោះរបៀបដំណើរការរបស់គម្រោងសិល្បៈស-ស។ យើងព្យាយាមចាកចេញពីគំរូអង្គការក្រៅរដ្ឋាភិបាលរបៀបចាស់ ព្រោះអង្គការទាំងនេះតែងតែមានកាតព្វកិច្ចដ៏ធ្ងន់ធ្ងរក្នុងការបំពេញនូវការរំពឹងទុករបស់អ្នកផ្ដល់ជំនួយរបស់គេ។ ដោយមិនមានជាប់ជំពាក់ក្នុងរចនាសម្ព័ន្ធដ៏តឹងរឹងគម្រោងសិល្បៈស-សអាចបត់បែន និងប្រែប្រួលទៅតាមបរិបទនិងកាលៈទេសៈជាក់ស្ដែង ដើម្បីបំពេញនូវតម្រូវការរបស់សហគមន៍ដែលយើងធ្វើការជាមួយ។ យើងជឿជាក់ថាថវិកាគួរចំណាយទៅលើការបង្កើតបទពិសោធន៍

---

[៨] គំនិតជុំវិញរចនាសម្ព័ន្ធសាកល្បងរបស់គម្រោងសិល្បៈស-ស ត្រូវបានបង្ហាញជាលើកដំបូងជាមួយ ដេវីឌ ហ្គាន់ (David Gunn) នៅឯវេទិកាសង្គមរបស់អង្គការសហប្រជាជាតិ ២០១១ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

និងចំណេះដឹងថ្មីៗ និងចំពោះប្រជាជននិងសហគមន៍ដែលយើងធ្វើការជាមួយ។ ហេតុដូច្នេះហើយ ថវិការបស់យើងស្ទើរតែទាំងស្រុងត្រូវបានចំណាយលើផ្នែកទាំងនេះ។ រាល់សមាជិកទាំង៣របស់ក្រុមស្ទាវសិល្បៈគឺស្ម័គ្រចិត្តបរិច្ចាគពេលវេលានិងកម្លាំងនៅក្នុងការងារគម្រោង។ ទើបតែនៅឆ្នាំ២០១៣នេះប៉ុណ្ណោះ ដែលយើងបានចាប់ផ្តើមផ្តល់ប្រាក់ខែដល់សិស្សម្នាក់ក្នុងតួនាទីជាបុគ្គលិកជំនួយការក្រៅម៉ោងនិងផ្តល់ប្រាក់ខែដល់លីណាក្នុងតួនាទីជាប្រធានកម្មវិធីនិវាសដ្ឋានសិល្បៈ ពិសោធន៍ (ដែលខ្ញុំនឹងរៀបរាប់នៅខាងក្រោម)។

ប៉ុន្តែតាមការជាក់ស្តែងវិញនោះ គឺយើងនៅឆ្ងាយនៅឡើយពីស្ថានភាពទូទៅមួយដែលអាចហៅថា "សមរម្យ" បាន។ បើនិយាយតែវិស័យសិល្បៈប៉ុណ្ណោះក៏ឃើញថា គោលនយោបាយជាតិផ្នែកសិល្បៈនិងវប្បធម៌ផ្តោតទៅលើតែការការពារនិងស្តារអ្វីៗដែលមានពីមុនមក។ ការប្តេជ្ញានេះមានបង្ហាញយ៉ាងច្បាស់នៅឯសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលអង្គការសហប្រជាជាតិសម្រាប់ការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌(UNESCO) បានជួយគាំទ្រដល់មហាវិទ្យាល័យបុរាណវិទ្យាមហាវិទ្យាល័យនគរូបនីយវិទ្យាតាំងពីឆ្នាំ១៩៩៣មកដើម្បី "អភិវឌ្ឍធនធានមនុស្សសម្រាប់ការងារថែរក្សាកេរ្តិ៍តំណែលវប្បធម៌"[៩]។ ពេលដែលការយកចិត្តទុកដាក់លើការអភិរក្សនេះមានសារៈសំខាន់នោះ វាក៏ផាកចេញដែរអំពីឱកាសសម្រាប់អភិវឌ្ឍភាពច្នៃប្រឌិតថ្មីៗ។ ហេតុដូច្នេះហើយគម្រោងសិល្បៈស-សប្រកាន់នូវជំហរការបង្កើតថ្មី និងការចូលរួមចំណែករបស់ប្រជាជនខ្មែរជំនាន់ថ្មីនៅក្នុងវិស័យសិល្បៈ។ សំណាង លីណា និងខ្ញុំមានជំនឿថាសិល្បៈគឺជាសេរីភាព ហើយយើងយល់ថាយើងគួរចូលរួមចំណែកក្នុងការបង្កើតសិល្បៈថ្មី និងចំណេះដឹងថ្មីៗ យើងមិនចំណាយពេលច្រើនពេកដើម្បីប្រឹងស្វែងរកអត្ថន័យ "តើសិល្បៈសហសម័យជាអ្វី?"នោះទេ ប៉ុន្តែយើងព្យាយាមស្វែងរកលទ្ធភាពថ្មីនៅក្នុងការបង្កើតនិងប្រឡូកនៅក្នុងសិល្បៈ និងកសាងបរិកាសនិងការគាំទ្រដែលលទ្ធភាពថ្មីៗអាចកើតឡើងបាន។

គម្រោងសិល្បៈស-សដំណើរការនៅក្នុងកាលៈទេសៈកម្ពុជាបច្ចុប្បន្នដែលខ្វះខាតរចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ការសិក្សានិងចូលរួមនៅក្នុងវិស័យសិល្បៈសហសម័យក៏ដូចជាមានវត្តមានអង្គការក្រៅរដ្ឋាភិបាលដ៏ច្រើនលើសលុបនិងបរិកាសនយោបាយដូចបានរៀបរាប់ខាងលើ។ យើងសង្ឃឹមថាអាចបង្កើតមជ្ឈដ្ឋានមួយដែលសិស្សក្មេងៗ ក៏ដូចជាសិល្បករក្មេងៗ ព្រមទាំងប្រជាជនខ្មែរសាមញ្ញ ដូចជាប្រជាជននៅប៊ូឌីងនេះអាចរៀន ស្វែងរក ចូលរួម និងបញ្ចេញយោបល់របស់គេតាមរយៈសិល្បៈ។ នៅក្នុងដំណើរការរៀនជាមួយគ្នានេះ យើងសង្ឃឹមថាអ្នកចូលរួមអាចស្វែងរកមធ្យោបាយ ដើម្បីរើបម្រះពីទម្រង់ការចូលរួមក្នុងសិល្បៈដែលបានកំណត់រួចស្រាប់ និងចាប់យកលទ្ធភាពថ្មីៗវិញ។

បន្ទាប់ពីបានរៀបចំសកម្មភាពសិល្បៈផ្សេងៗអស់រយៈពេល៣ឆ្នាំមកគម្រោងសិល្បៈស-សបច្ចុប្បន្នកំពុងបន្តទៅកាន់ដំណាក់កាលថ្មី និងផ្តោតសាជាថ្មីចំពោះកម្មវិធីដែលតែងវិវត្តរបស់យើង។ នៅដើមឆ្នាំ២០១៣ បន្ទាប់ពីកម្មវិធីប្រមូលថវិកាតាមរយៈប្រព័ន្ធអ៊ីនធឺណិតដ៏ជោគជ័យមក យើងបានសម្ពោធកម្មវិធីនិវាសដ្ឋានសិល្បៈពិសោធន៍សម្រាប់ឲ្យសិល្បករខ្មែរ និងបរទេស អាចចំណាយពេល៦សប្តាហ៍ ស្នាក់នៅនិងធ្វើការនៅ

---

[៩] www.whitebuilding.org

*ក្នុងបន្ទប់សិល្បៈរបស់យើងនៅប៊ូឌីង។ សិល្បករក្នុងនិវាសដ្ឋានត្រូវបានផ្តល់ជូននូវការឧបត្ថម្ភថវិកា និងសេរីភាពក្នុងការស្វែងរកវិធីសាស្ត្រថ្មីៗក្នុងការបង្កើតសិល្បៈ ដោយ ហ៊ានប្រថុយ និងសាកល្បងជាមួយគំនិតថ្មីៗ។ និវាសដ្ឋាននេះផ្តោតសំខាន់លើដំណើរការអនុវត្តការងារ ការរៀនសូត្រ និងការចែករំលែកបទពិសោធន៍ចំណេះដឹង។ នៅក្នុងវិវាសដ្ឋាននីមួយៗ នឹងមិនមានកម្មវិធីពិព័រណ៍ទេ។ ផ្ទុយទៅវិញ សិល្បករក្នុងនិវាសដ្ឋានត្រូវបានលើកទឹកចិត្តឲ្យចែក រំលែកចំណេះដឹងតាមរយៈកម្មវិធីសាធារណៈក្នុងទម្រង់ផ្សេងៗដូចជា បាឋកថា ការបើកស្ទូឌីយ៉ូសិក្ខាសាលាឬក្នុងទម្រង់ផ្សេងទៀត។បន្ថែមពីនេះនឹងមានការបោះពុម្ពផ្សាយឯកសារសម្រាប់ចែករំលែកអំពីដំណើរការ និងអ្វីដែលបានរៀនអំពីកម្មវិធីនិវាសដ្ឋាននីមួយៗ ដល់សហគមន៍សិល្បៈខ្មែរ។*

*ទន្ទឹមនឹងកម្មវិធីនិវាសដ្ឋានថ្មីនេះការងារជាឯកសារ និងបណ្ណសាររបស់យើងនៅតែបន្ត។ នៅទសវត្សចុងក្រោយនេះ អគារចាស់ៗជាច្រើននៅភ្នំពេញត្រូវបានប្រែក្លាយឬក៏កម្ទេចចោលពេលដែលការអភិវឌ្ឍន៍ក្រុងកំពុងប្រព្រឹត្តិទៅយ៉ាងគំហុក។ តែទោះជាយ៉ាងណា ប៊ូឌីងគឺជាអគារមួយក្នុងចំណោមស្ថាបត្យកម្មប្រវត្តិសាស្ត្រមួយចំនួន ដែលកំពុងនៅតែឈរតទល់នឹងការអភិវឌ្ឍន៍នេះ។ ដោយយល់ពីអនាគតមិនស្ថិតស្ថេររបស់សហគមន៍នេះគម្រោងសិល្បៈស-សបានសហការជាមួយក្រុមប្រព័ន្ធផ្សព្វផ្សាយប្រចាំនៅអូស្ត្រាលី* Big Stories *ដើម្បីបង្កើតនូវបណ្ណសារអេឡិកត្រូនិកមួយ[១០] ដែលប្រមូលនូវស្នាដៃសិល្បៈសោតទស្សន៍បង្កើតដោយសិស្សរបស់យើងនិងប្រជាជននៅប៊ូឌីង។ ប្រព័ន្ធព័ត៌មាននៅលើអ៊ីនធឺណិតនេះនឹងប្រមូលផ្តុកផងដែរនូវស្នាដៃបែបសហការមួយចំនួនរបស់សិល្បករខ្មែរនិងបរទេស ដែលបានបង្កើតនៅក្នុងប៊ូឌីង។ ដូច្នេះ បណ្ណសារនេះនឹងផ្តល់នូវធនធានសោតទស្សន៍ស្តីអំពីប្រវត្តិបច្ចុប្បន្ននៃវប្បធម៌ និងសហគមន៍ក្នុងទីក្រុងដ៏ស្មុគស្មាញ និងសំបូរបែបមួយនេះ។ បណ្ណសារនេះ នឹងដាក់ជូនប្រើប្រាស់តាមប្រព័ន្ធ អ៊ីនធឺណិត ដូច្នេះហើយយើងសង្ឃឹមថានឹងអាចបម្រើជាធនធានមានប្រយោជន៍សម្រាប់ប្រជាជននៅប៊ូឌីងក៏ដូចជាអ្នកស្រាវជ្រាវ សិល្បករ និងអ្នករៀបចំកម្មវិធីសិល្បៈនានា។*

*បើទោះជាយើងបានសាកស្បងធ្វើការងារជាច្រើនបែបយ៉ាងហើយ និងនៅមានសក្តានុពលភាពជាច្រើនទៀតក៏ដោយគម្រោងសិល្បៈស-សក៏មានកម្រិតដោយសារតែទម្រង់របស់ខ្លួនដែរ។ ថវិកាទ្រទ្រង់ដើម្បីបន្តដំណើរការកម្មវិធី គឺជាបញ្ហាប្រឈមចម្បងជានិច្ចរបស់យើង។ ក្នុងនាមជាក្រុមការងារដែលមិនមានរចនាសម្ព័ន្ធដូចជាស្ថាប័នផ្លូវការនិងមានតែ សំណាង លីណា និងខ្ញុំ បីនាក់គត់ (ដែលយើងម្នាក់ៗត្រូវប្រឹងប្រែងបង្កើតការងារសិល្បៈរៀងៗខ្លួនផងនោះ) ជាអ្នកដើរតួនាទីសំខាន់នៅក្នុងគម្រោងក៏បង្ហាញនូវហានិភ័យច្រើនដែរ។ ប៉ុន្តែទោះជាណាក្តី លទ្ធភាពក្នុងការបត់បែននិងវិវត្តក្នុងការងាររបស់យើង គឺជាកត្តាដ៏ចម្បងរបស់គម្រោងសិល្បៈស-ស ដើម្បីឲ្យគម្រោងនៅមានភាពទាក់ទងសម្រាប់សហគមន៍សិល្បៈខ្មែរ។ ទន្ទឹមនឹងនេះកត្តាចម្បងផងដែរនោះគឺការដឹងខ្លួនជាប់ជានិច្ចនិងការវាយតម្លៃលើកម្លាំងរបស់ក្រុមយើងក៏ដូចជាលើវេទិកាបច្ចុប្បន្នក្នុងការប្រឡូកចូលរួមក្នុងវិស័យសិល្បៈសហសម័យដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នៅក្នុង*

---

១០ www.whitebuilding.org

## *ចែករំលែកចំណេះដឹង និងរៀនជាមួយគ្នា*

*កាលៈទេសៈ បច្ចុប្បន្ននៃការអប់រំសិល្បៈមិនគ្រប់គ្រាន់ និងការចូលរួមដ៏តិចតួចពីសំណាក់ប្រជាជនខ្មែរសាមញ្ញ នៅក្នុងវិស័យសិល្បៈ ក្រុមស្ពាវសិល្បៈ និងគម្រោងសិល្បៈស-ស ខិតខំចែករំលែក រៀនសូត្រ សហការ ចូលរួម និងរីកចម្រើនក្នុងស្មារតីនៃការសិក្សាអប់រំសេរីនិងរៀនសូត្រជាមួយគ្នា។*